**Project Activities:**

1st Aug: Strings Monthly Meeting with JICA HQ/ Cambodia Office
9th Aug: Meeting with Mr. Un San, CCN
12th Aug: Meeting with Mr. Chhoun Pheak (Project Short-term Consultant)
17th Aug:
- Equipment Handover (Laptops & Projectors) to Dr. Touch Sokneang, HRDD
- NGO-JICA Health Sector Meeting

19th Aug: Discussion Session with the Technical Working Group (TWG) about drafting the national guideline of In-Service Training (INSET) outline.
22nd Aug: Meeting with GIZ (ISPH)
24th-26th Aug: 3-day Workshop for Developing Guideline of INSET for Nurses, Kampot Province
30th Aug: Meeting with IT expert, CCN

**សកម្មភាពគម្រោង៖**

ថ្ងៃទី ១ ខែសីហា៖ កិច្ចប្រជុំប្រចាំខែជាមួយទីស្នាក់ការកណ្តាល **JICA** និងការិយាល័យ **JICA** តំណាងប្រទេសកម្ពុជា។
ថ្ងៃទី ៩ សីហា៖ ជួបជាមួយលោក អ៊ុន សាន (**CCN**)
ថ្ងៃទី ១២ សីហា៖ ជួបជាមួយលោកឈួន ភក្តិ (អ្នកប្រឹក្សាគម្រោងរយៈពេលខ្លី)
ថ្ងៃទី ១៧ ខែសីហា៖
- ការប្រគល់ឧបករណ៍ (កុំព្យូទ័រយួរដៃ និងម៉ាស៊ីនបញ្ចាំងស្លាយ) ជូនលោកស្រីវេជ្ជបណ្ឌិត ទូច សុខនាង (**HRDD**)
- កិច្ចប្រជុំជាមួយវិស័យសុខាភិបាល នៃ **NGO-JICA**

ថ្ងៃទី ១៩ ខែសីហា៖ ប្រជុំពិភាក្សាជាមួយក្រុមការងារបច្ចេកទេសអំពីការរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំថ្នាក់ជាតិសម្រាប់ការបណ្តុះបណ្តាលក្នុងពេលបម្រើការងាររបស់គិលានុបដ្ឋាក
ថ្ងៃទី ២២ ខែសីហា៖ កិច្ចប្រជុំជាមួយ **GIZ** (**ISPH**)
ថ្ងៃទី ២៤ ដល់ ២៦ ខែសីហា៖ សិក្ខាសាលារយៈពេល ៣ ថ្ងៃអំពីការអភិវឌ្ឍគោលការណ៍ណែនាំថ្នាក់ជាតិសម្រាប់ការបណ្តុះបណ្តាលក្នុងពេលបម្រើការងាររបស់គិលានុបដ្ឋាកក្នុងប្រទេសកម្ពុជានៅខេត្តកំពត
ថ្ងៃទី ៣០ ខែសីហា៖ ការជួបជាមួយអ្នកជំនាញ **IT** (**CCN**)

## Equipment Handover to HRDD for Distribution
## ការប្រគល់ឧបករណ៍ជូន HRDD ដើម្បីចែកចាយ

**In order to facilitate the technical working group (TWG) for developing the guideline of In-Service Training (INSET) for Nurses, Project for Strengthening In-Service Training System in Cambodia (Strings) handed over equipment, which included 11 laptops and 2 projectors, to the Human Resources Development Department (HRDD), Ministry of Health (MOH), on August 17th, 2022.**
**This equipment will then be distributed by HRDD to the Hospital Service Department (HSD) of MOH, Calmette Hospital, Khmer-Soviet Friendship Hospital, National Pediatric Hospital, Cambodian Council of Nurses (CCN), and Cambodian Association of Nurses (CAN).**

ដើម្បីជួយសម្រួលដល់ក្រុមការងារបច្ចេកទេសក្នុងការអភិវឌ្ឍគោលការណ៍ណែនាំថ្នាក់ជាតិ សម្រាប់ការបណ្តុះបណ្តាលក្នុងពេលបម្រើការងាររបស់គិលានុបដ្ឋាក គម្រោងពង្រឹងប្រព័ន្ធបណ្តុះបណ្តាលក្នុងពេលបម្រើការងារនៅកម្ពុជា (Strings) បានប្រគល់ឧបករណ៍ដែលរួមមាន កុំព្យូទ័រយួរដៃចំនួន ១១គ្រឿង និងម៉ាស៊ីនបញ្ចាំងស្លាយ ចំនួន ២ ដល់នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស នៃក្រសួងសុខាភិបាល នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២។
ឧបករណ៍ទាំងនេះ នឹងបន្តចែកចាយដោយនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស ដើម្បីប្រគល់ជូនដល់នាយកដ្ឋានមន្ទីរពេទ្យ មន្ទីរពេទ្យកាល់ម៉ែត មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មន្ទីរពេទ្យកុមារជាតិ គណៈគិលានុបដ្ឋាកកម្ពុជា និងសមាគមគិលានុបដ្ឋាកកម្ពុជា។



Equipment Handover to Dr. Touch Sokneang and Dr. Sam Sina of HRDD

## Discussion Session with the Technical Working Group
## ការប្រជុំពិភាក្សាជាមួយក្រុមការងារបច្ចេកទេស


Discussion Session with TWG on 19th AUG, NMCHC

**Before starting the workshop for developing the national guideline of INSET for nurses, the Project had arranged a Zoom meeting with the TWG in order to discuss on the content, and outlines of the guideline.**
**13 people participated, including H.E Prof. Mam Bunsocheat, HRDD (2), HSD (2), national hospitals (3), CCN (1), CAN (1),and project members (3).**

មុននឹងចាប់ផ្តើមធ្វើសិក្ខាសាលាសម្រាប់អភិវឌ្ឍគោលការណ៍ណែនាំថ្នាក់ជាតិសម្រាប់ការបណ្តុះបណ្តាល ក្នុងពេលបម្រើការងាររបស់គិលានុបដ្ឋាកនៅប្រទេសកម្ពុជាក្រុមការងារគម្រោង បានរៀបចំកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ Zoom ជាមួយក្រុមការងារបច្ចេកទេស (TWG) ដើម្បីពិភាក្សាលើខ្លឹមសារ និងគ្រោងនៃគោលការណ៍ណែនាំ។
អ្នកចូលរួមមានចំនួន១៣នាក់រួមមាន ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនសុជាតិ និង សមាជិកនៃក្រុមការងារបច្ចេកទេស៖
នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស (២) / នាយកដ្ឋានមន្ទីរពេទ្យ (២) / មន្ទីរពេទ្យជាតិ (៣) / គណៈគិលានុបដ្ឋាកកម្ពុជា (១) / សមាគមគិលានុបដ្ឋាកកម្ពុជា (១) / និងសមាជិកគម្រោង (៣)។

# 3-day Workshop for Developing Guideline of In-Service Training for Nurses in Kampot Province

## សិក្ខាសាលាស្តីពីការអភិវឌ្ឍគោលការណ៍ណែនាំថ្នាក់ជាតិសម្រាប់ការបណ្តុះបណ្តាលក្នុងពេលបម្រើការងាររបស់គិលានុបដ្ឋាកធ្វើនៅខេត្តកំពត

**Strings project plans to organize 3-time workshops in August, September, and October 2022 to develop the guideline of INSET for nurses. The first workshop was conducted in Kampot province for 3 days, from 24th to 26th of August.**

**The TWG and the steering committee participated in this workshop, which consisted of members from HRDD and HSD of MOH, National Hospitals (Calmette Hospital, Khmer-Soviet Friendship Hospital, National Pediatric Hospitals), CCN and CAN.**

**During the workshop, the members had group discussions to draft the outline and contents of the national guideline and presented their progress reports.**

**Overall, this workshop contributed to the progress of guideline development and will be completed by the end of 2022.**



**All the partcipants of the 3-day Workshop at Kampot Province**

គម្រោងសហប្រតិបត្តិការបច្ចេកទេស (Strings Project) បានរៀបចំសិក្ខាសាលាលើកទីមួយនៅខេត្តកំពត រយៈពេល ៣ ថ្ងៃ ចាប់ពីថ្ងៃទី ២៤ ដល់ថ្ងៃទី ២៦ ខែសីហា ដើម្បីអភិវឌ្ឍគោលការណ៍ណែនាំថ្នាក់ជាតិនៅខេត្តកំពត។ គម្រោងនេះនឹងបន្តរៀបចំសិក្ខាសាលាចំនួន៣លើក នៅក្នុងខែសីហា កញ្ញា និងតុលា ឆ្នាំ ២០២២ ដើម្បីអភិវឌ្ឍគោលការណ៍ណែនាំថ្នាក់ជាតិ សម្រាប់ការបណ្តុះបណ្តាលក្នុងពេលបម្រើការងាររបស់គិលានុបដ្ឋាកក្នុងប្រទេសកម្ពុជា ។

សិក្ខាសាលានេះផងដែរ គឺមានការចូលរួមពីក្រុមការងារបច្ចេកទេស និងគណៈកម្មការគ្រប់គ្រងរបស់គម្រោង ដោយមានសមាជិកមកពីនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និង នាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល មន្ទីរពេទ្យជាតិ (មន្ទីរពេទ្យកាល់ម៉ែត មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត និងមន្ទីរពេទ្យកុមារជាតិ) គណៈគិលានុបដ្ឋាកកម្ពុជា និងសមាគមគិលានុបដ្ឋាកកម្ពុជា។

ក្នុងអំឡុងពេលសិក្ខាសាលាសមាជិករបស់ក្រុមការងារបច្ចេកទេស បានធ្វើការពិភាក្សាជាក្រុមដើម្បីរៀបចំគោលការណ៍ណែនាំថ្នាក់ជាតិនិងធ្វើបទបង្ហាញអំពីរបាយការណ៍វឌ្ឍនភាពផងដែរ។ សិក្ខាសាលាទាំង៣ថ្ងៃនេះ បានរួមចំណែកដល់វឌ្ឍនភាពនៃការអភិវឌ្ឍសេចក្តីណែនាំថ្នាក់ជាតិដែលនឹងបញ្ចប់នៅចុងឆ្នាំ២០២២។



**The Steering Committee during the presentation**



**Ms. Akemi Kamitaira discussed the progress of the presentations**



**The participants took part in the discussion about the outline of the guideline**



**Dr. Koy Virya presented after group discussion**



**Activities during the group discussions**



**Mr. Pak Sopheak presented after group discussion**



**Activities during the group discussions**



**Ms. Pay Soklim presented after group discussion**



**Activities during the group discussions**

## Upcoming Activities (សកម្មភាពបន្ត)

- **12-14th Sep: 2nd Workshop for developing guidelines in Kampong Cham Province**
- **29th Sep: 3rd CPD Workshop hosted by GLO+UHC Project, Thailand**
- ថ្ងៃទី ១២ ដល់ ១៤ ខែកញ្ញា៖ សិក្ខាសាលាលើកទី ២ សម្រាប់អភិវឌ្ឍគោលការណ៍ណែនាំនៅខេត្តកំពង់ចាម
- ថ្ងៃទី ២៩ ខែកញ្ញា៖ សិក្ខាសាលា **CPD** លើកទី ៣ រៀបចំដោយគម្រោង **GLO+UHC** នៃប្រទេសថៃ


**CONTACT INFORMATION**

**Project Office:**

- **Ministry of Health (MoH)**

Department of Human Resource Development (HRDD)
No. 80, Samdach Penn Nouth Blvd (289), Sangkat Beoungkak 2, Tuol Kork District, Phnom Penh, Cambodia

- **National Maternal and Child Health Center (NMCHC)**

N° 31A, Rue de France (St. 47), Sangkat Sras Chork, Daun Penh District, Phnom Penh

**Email: info@jicastrings.com**